# តួនាទីរបស់ទីប្រឹក្សាពិសេសឬគណៈកម្មាធិការពិនិត្យរបស់អង្គជំនុំជម្រះវិសាមញ្ញ

*អ៊ែន ហាញខុល និង ចន ឈីផ័ររី*

ទន្ទឹមនឹងពេលដែលអង្គជំនុំជម្រះវិសាមញ្ញ កំពុងស្វះស្វែងរកថវិកាសម្រាប់បំពេញការខ្វះខាត ម្ចាស់ជំនួយខ្លះកំពុងតែពិចារណា ថាតើគួរតែផ្តល់ជំនួយដោយដាក់លក្ខខណ្ឌឲ្យមានការត្រួតពិនិត្យមើលជាអន្តរជាតិទៅលើសេចក្តីសម្រេចផ្នែកហិរញ្ញវត្ថុនិងរដ្ឋបាលរបស់ អង្គជំនុំជម្រះវិសាមញ្ញដែរឬយ៉ាងណា ។ សវនកម្មទៅលើផ្នែកខ្លះរបស់អង្គជំនុំជម្រះវិសាមញ្ញកាលពីឆ្នាំ២០០៧ បានឲ្យលទ្ធផលស្រប ទៅនឹងគំនិតដែលថា ការត្រួតពិនិត្យមើលឲ្យបានតឹងរ៉ឹងជាងមុន ទៅលើដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ គឺជារឿងចាំបាច់ ។ ម្ចាស់ជំនួយនិងអង្គការក្រៅរដ្ឋាភិបាលខ្លះបានស្នើឲ្យមានការ បង្កើតតំណែងទីប្រឹក្សាអន្តរជាតិពិសេសមួយនិង ឬគណៈកម្មាធិការត្រួតពិនិត្យ ដើម្បីដាក់ជាលក្ខខណ្ឌទៅនឹងការផ្តល់ជំនួយ ។ ទីប្រឹក្សាពិសេសឬគណៈកម្មាធិការនេះ នឹងត្រួតពិនិត្យមើលនិងផ្តល់ យោបល់ទៅលើដំណើរការរដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញ ដើម្បីធានាឲ្យបាននូវឯករាជ្យភាពនិងតម្លាភាពរបស់តុលាការនេះ ។ អនុស្សារណៈនេះនឹងបង្ហាញអំពីការយល់ឃើញរបស់យើង ចំពោះរបៀបដែលតួនាទីទាំងនេះ អាចលើកកម្ពស់យ៉ាង មានប្រសិទ្ធិភាពបំផុតនូវប្រសិទ្ធិភាពការងារ តម្លាភាព និងការទទួលខុសត្រូវនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។

**របៀបផ្សេងៗទៀត :**

ទាំងកិច្ចព្រមព្រៀងរវាងកម្ពុជានិងអង្គការសហប្រជាជាតិ និងច្បាប់កម្ពុជាបង្កើតអង្គជំនុំជម្រះវិសាមញ្ញមិនបានចែងអំពីការបង្កើតទីប្រឹក្សាអន្តរជាតិពិសេស ឬគណៈកម្មាធិការត្រួតពិនិត្យនេះទេ ។ ជាងនេះទៅទៀត មានតែនៅក្នុងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនប៉ុណ្ណោះ ដែលមានបង្កើតតំណែងស្រដៀងគ្នានេះ ។ សាលាជំនុំជម្រះក្តីអន្តរជាតិស្ទើតែទាំងអស់សុទ្ធតែជាអង្គការមួយរបស់អង្គការសហប្រជាជាតិ ឬកើតចេញពីបេសកកម្មរបស់អង្គការសហប្រជាជាតិ ដូច្នេះហើយសាលាជំនុំជម្រះក្តីទាំងនេះត្រូវស្ថិតនៅក្រោមយន្តការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិ ។ មានតែតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនប៉ុណ្ណោះដែលស្រដៀងគ្នាទៅនឹងអង្គជំនុំជម្រះវិសាមញ្ញ ដែលត្រូវបានបង្កើតឡើង ដោយឯករាជ្យចេញពីអង្គការសហប្រជាជាតិ ហើយគណៈកម្មាធិការនាយករបស់តុលាការពិសេសនេះគឺជាគំរូដែលស្រដៀងគ្នាបំផុតសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ។

សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវី ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខក្រោម

ធម្មនុញ្ញសហប្រជាជាតិជំពូក៧ស្តីពីសន្តិភាពនិងសន្តិសុខ ។ មិនមានរចនាសម្ព័ន្ធត្រួតពិនិត្យឬធ្វើរបាយ-ការណ៍ឯករាជ្យណាមួយត្រូវបាន បង្កើតឡើងដើម្បីពិនិត្យមើលផ្នែករដ្ឋបាលរបស់សាលាជំនុំជម្រះក្តីទាំងនេះទេ ។ ប៉ុន្តែ តួនាទីនេះបានធ្លាក់ទៅលើអគ្គលេខាធិការដ្ឋាន សហប្រជាជាតិនិងក្រុមប្រឹក្សា សន្តិសុខនូវឯងដែលត្រូវពិនិត្យមើលរបាយការណ៍ប្រចាំឆ្នាំដែលធ្វើឡើងដោយប្រធានសាលាជំនុំជម្រះក្តី ។ គណៈវិនិច្ឆ័យពិសេសទទួលបន្ទុកឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅក្នុងប្រទេសទីម័រខាងកើត (Special Panels for Serious Crimes in East Timor) ត្រូវបានបង្កើតឡើងដោយទីភ្នាក់ងារអន្តរកាលសហប្រជាជាតិនៅក្នុងប្រទេសនោះ (UN Transitional Administrator) ។ អគ្គលេខាធិការសហប្រជាជាតិទទួលបន្ទុករាយការណ៍ជូនទៅក្រុមប្រឹក្សាសន្តិសុខរៀងរាល់៦ខែម្តង ស្តីអំពីដំណើរការរបស់គណៈវិនិច្ឆ័យពិសេសនេះ ប៉ុន្តែមិនមានយន្តការត្រួតពិនិត្យផ្សេងពីនេះត្រូវបានបង្កើតឡើងនោះទេ ។

ខុសប្លែកគ្នាពីសាលាជំនុំជម្រះក្តីខាងលើ តុលាការពិសេស សម្រាប់ប្រទេសសេរ៉ាឡេអូន មិនមែនជាស្ថាប័នរបស់អង្គការសហប្រជាជាតិនោះទេ ។ តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូននេះគឺជាតុលាការឯករាជ្យបង្កើតឡើងដោយសន្ធិសញ្ញារវាងអង្គការសហប្រជាជាតិនិងប្រទេសសេរ៉ាឡេអូន ។ តុលាការពិសេសនេះ មិនមែនទទួលបានថវិកាដោយផ្ទាល់ពីថវិការបស់សហប្រជាជាតិទេ តុលាការនេះទទួលបានថវិកាពីការបរិច្ចាគរបស់ប្រទេសផ្សេងៗ ។ ក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិមិនមានតួនាទីត្រួតពិនិត្យមើល ដោយផ្ទាល់នោះទេ ហើយអគ្គលេខាធិការដ្ឋានសហប្រជាជាតិក៏មិនមានបន្ទុកត្រួតពិនិត្យមើលថវិការបស់តុលាការនេះដែរ ។ ប៉ុន្តែកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងប្រទេសសេរ៉ាឡេអូនបានចែងថា ប្រទេសផ្តល់ជំនួយនឹងបង្កើតនូវគណកម្មាធិការនាយកមួយដែលមានអ្នកតំណាងម្នាក់របស់អគ្គលេខាធិការសហប្រជាជាតិ ប្រទេសម្ចាស់ជំនួយនិងរដ្ឋម្ចាស់ផ្ទះ ។ លើសពីនេះទៅទៀត លក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនតម្រូវឲ្យប្រធានតុលាការពិសេសនេះធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីអំពីដំណើការនិងសកម្មភាពរបស់តុលាការជូនទៅអគ្គលេខាធិការសហប្រជាជាតិ និងរដ្ឋាភិបាលប្រទេសសេរ៉ាឡេអូន ។

## តំណែងថ្មីឬគណៈកម្មាធិការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ

យើងជឿជាក់ថា ទីប្រឹក្សាអន្តរជាតិពិសេសឬគណៈកម្មាធិការ ត្រួតពិនិត្យអាចជំរុញឲ្យមានដំណើការដែលមានតម្លាភាព និងមានប្រសិទ្ធភាពនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញតាមរយៈការបំពេញនូវតួនាទីដែលស្រដៀងគ្នាទៅនឹងតួនាទីរបស់គណៈកម្មាធិការនាយករបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ។ កិច្ចការ សំខាន់ៗមួយចំនួនដែលត្រូវបំពេញមានដូចជា ៖

- ផ្តល់យោបល់និងគោលនយោបាយទៅឲ្យមន្ត្រីជាន់ខ្ពស់របស់ អង្គជុំនុំជម្រះវិសាមញ្ញជុំវិញផ្នែកដែលមិនទាក់ទងនឹងបញ្ហាច្បាប់ ទាំងអស់នៃដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។
- ចូលរួមរៀបចំថវិកាប្រចាំឆ្នាំរបស់អង្គជំនុំជម្រះវិសាមញ្ញ ។
- ពិនិត្យមើលរបាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍រដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញ ។
- ផ្ញើរបាយការណ៍ស្តីអំពីដំណើរការថវិកានិងដំណើរការផ្នែកផ្សេងៗដែលមិនទាក់ទងនឹងបញ្ហាច្បាប់ជូនទៅរាជរដ្ឋាភិបាលកម្ពុជា អគ្គលេខាធិការសហប្រជាជាតិនិងម្ចាស់ជំនួយសំខាន់ៗ ។
- ផ្តល់យោបល់ទៅឲ្យរដ្ឋាភិបាលកម្ពុជា អគ្គលេខាធិការសហប្រជាជាតិនិងម្ចាស់ជំនួយអន្តរជាតិសំខាន់ជុំវិញបញ្ហាដែលមិនទាក់ទងនឹងបញ្ហាច្បាប់ និង
- ជួយធានាថា អង្គជំនុំជម្រះវិសាមញ្ញមានថវិកាគ្រប់គ្រាន់សម្រាប់ដំណើរការរបស់ខ្លួន ។

តំណែងទីប្រឹក្សាថ្មីណាមួយ និង បុគណៈកម្មាធិការត្រួតពិនិត្យណាមួយត្រូវតែគោរពទៅតាមកិច្ចព្រមព្រៀងនិងច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ ដោយសារមូលហេតុនេះ តួនាទីទីប្រឹក្សា បុគណៈកម្មាធិការនេះ ត្រូវតែមានឯករាជ្យភាពពីរចនាសម្ព័ន្ធរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ យើងជឿជាក់ថា ទាំងទីប្រឹក្សានិងគណៈកម្មាធិការត្រួតពិនិត្យអាចជួយកែលម្អដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញនិងដើរតួនាទីជាអ្នកទំនាក់ទំនងរវាងតុលាការនិងភាគីសំខាន់ៗ នៅក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ទីប្រឹក្សាអាចធ្វើសហប្រតិបត្តិការជាមួយមន្ត្រីអង្គជំនុំជម្រះវិសាមញ្ញជារៀងរាល់ថ្ងៃ ចំណែកឯគណៈកម្មាធិការនាយកអាចទទួលខុសត្រូវចំពោះការវាយតម្លៃយូរៗម្តង ។

ប្រសិនបើតំណែងទីប្រឹក្សាត្រូវបានបង្កើតឡើងមែន យើងជឿជាក់ថា វាគួរតែជាតំណែងដែលត្រូវទទួលកិច្ចការពីអង្គការ សហប្រជាជាតិនិងដែលត្រូវតែងតាំងដោយអគ្គលេខាធិការសហប្រជាជាតិដោយមានការពិភាក្សាជាមួយរដ្ឋាភិបាលកម្ពុជានិងម្ចាស់ជំនួយសំខាន់ៗ ។ ប្រសិទ្ធិភាពនិងឥទ្ធិពលនយោបាយរបស់ ទីប្រឹក្សានេះនឹងអាស្រ័យទៅលើជំនាញការទូតនៅក្នុងការគ្រប់គ្រងតុលាការរបស់បុគ្គលនេះ ។ អ្នកកាន់តំណែងនេះគួររាយការណ៍ដោយផ្ទាល់ទៅកាន់អគ្គលេខាធិការសហប្រជាជាតិនិងមានលទ្ធភាពអាចពិភាក្សាជាមួយម្ចាស់ជំនួយទាំងអស់ ក៏ដូចជាជាមួយមន្ត្រីអង្គ ជំនុំជម្រះវិសាមញ្ញ ។

ទីប្រឹក្សាដែលបំពេញតាមការរៀបរាប់ខាងលើ គួរតែអាច បំពេញបាននូវកិច្ចការមួយចំនួន ។ ទីប្រឹក្សាជាន់ខ្ពស់ដែលមានប្រសិទ្ធិ ភាពអាចប្រតិកម្មយ៉ាងឆាប់រហ័សនិងយ៉ាងស្វាហាប់នៅពេលដែលបញ្ហាណាមួយកើតឡើង ។ ទីប្រឹក្សាដែលមានប្រសិទ្ធភាពអាចកសាងទំនាក់ទំនងនិងទំនុកចិត្តជាមួយមន្ត្រីអង្គជំនុំជម្រះវិសាមញ្ញ និងអ្នកមាន ផលប្រយោជន៍ទាក់ទងផ្សេងទៀត ។ យើងជឿជាក់ថា កិច្ចប្រជុំ

ក្រៅផ្លូវការដោយទៀងទាត់ក៏ជាចំណុចរួមផ្សំនៅក្នុងការកសាងការត្រួតពិនិត្យមួយដែលមានប្រសិទ្ធិភាពដែរ ។

គណៈកម្មាធិការនាយកអាចរួមមានអ្នកតំណាងពីប្រទេសម្ចាស់ជំនួយសំខាន់ៗមួយចំនួន ក៏ដូចជាអ្នកតំណាងពីអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា ។ ការរៀបចំបែបនេះនឹងអាចមានផលប្រយោជន៍ ដោយអាចធ្វើឲ្យអង្គជំនុំជម្រះវិសាមញ្ញមានការឆ្លើយតបច្រើនជាងមុន តបទៅនឹងយោបល់របស់អ្នកដែលមានផលប្រយោជន៍ពាក់ព័ន្ធ និងប្រហែលជាអាចធ្វើការសម្រេចចិត្តផ្សេងៗ មានតម្លាភាព ។ ប្រសិទ្ធភាពរបស់គណៈកម្មាធិការនាយកនេះនឹងអាស្រ័យទៅលើលទ្ធភាពដែលសមាជិកគណៈកម្មាធិការអាចធ្វើការជាមួយគ្នាសកម្មដល់កម្រិតណា ។ ប្រសិនបើគណៈកម្មាធិការនេះត្រូវបានបង្កើតឡើងមែន គណៈកម្មាធិការនាយកនេះគួរតែមានទម្រង់តូច ( ខ.សមាជិកពី៣-៥នាក់) ដែលអាចអនុញ្ញាតឲ្យដំណើរការមានប្រសិទ្ធភាពនិង ស្វាហាប់ ។ សមាជិករបស់គណៈកម្មាធិការនាយកនេះគួរតែ តែងតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ បន្ទាប់ពីការពិភាក្សាជាមួយអ្នកដែលមានផលប្រយោជន៍ពាក់ព័ន្ធ ។

បើទោះបីជាតំណែងទីប្រឹក្សា ឬក៏គណៈ កម្មាធិការនាយកត្រូវបានបង្កើតឡើង ការត្រួតពិនិត្យឬការគ្រប់គ្រងដែលមានប្រសិទ្ធភាព នឹងតម្រូវឲ្យមានការទំនាក់ទំនងជាទៀងទាត់រវាងមន្ត្រីអង្គជំនុំជម្រះវិសាមញ្ញនិងរដ្ឋាភិបាល ម្ចាស់ជំនួយតាមមធ្យោបាយការទូតដែលមិនសូវចេញមុខចេញមាត់ និងដោយផ្តោតទៅលើដំណោះស្រាយរួមដែលមានការចូលរួមពីភាគីផ្សេងៗ ទៅនឹងបញ្ហាប្រឈមមុខរបស់អង្គជំនុំ ជម្រះវិសាមញ្ញ ។